តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL Cambodia

# សេចក្តីថ្លែងការណ៍ព័ត៌មាន

# ទោះបីជាមានកំណែទម្រង់ខ្លះក៏ដោយ ការយល់ឃើញពីអំពើពុករលួយក្នុងវិស័យសាធារណៈរបស់ប្រទេសកម្ពុជាក្នុងឆ្នាំ២០១៥ នៅតែមានកម្រិតដូចគ្នាទៅនឹងឆ្នាំ២០១៤

**រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦** – ប្រទេសកម្ពុជាបានរក្សានូវពិន្ទុ២១ លើពិន្ទុ១០០ នៅក្នុងសន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយ (CPI) ដែលបានប្រកាសផ្សាយនៅថ្ងៃនេះដោយអង្គការតម្លាភាពអន្តរជាតិ។ សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយឆ្នាំ២០១៥នេះ បានបង្ហាញឲ្យឃើញថា បើទោះបីជាមានការកែលម្អ និងមានកំណែទម្រង់នៅក្នុងវិស័យជាក់លាក់មួយចំនួនក៏ដោយ ក៏វានៅតែមិនទាន់អាចផ្លាស់ប្តូរការយល់ឃើញរបស់ អ្នកជំនាញ សហគមន៍អាជីវកម្ម និងសាធារណៈជនបានឡើយ នៅពេលដែលអនុសាសន៍ជាចំបងសម្រាប់ការធ្វើកំណែទម្រង់ប្រឆាំងអំពើពុករលួយ ដែលផ្តល់ដោយអ្នកជំនាញប្រឆាំងអំពើពុករលួយមិនត្រូវបានយកមកអនុវត្ត។

សន្ទស្សន៍នេះ ផ្តល់ការវាយតម្លៃប្រចាំឆ្នាំនៃការយល់ឃើញពីអំពើពុករលួយក្នុងវិស័យសាធារណៈដោយដាក់ពិន្ទុឲ្យប្រទេសនានាទូទាំងសកលលោកផ្អែកលើមាត្រដ្ឋានពី ០ (ពុករលួយខ្លាំង) ទៅ ១០០ (ស្អាតស្អំខ្លាំង) ដែលក្នុងនោះប្រទេសកម្ពុជា ទទួលបានពិន្ទុ ២១ និងចំណាត់ថ្នាក់ ១៥០ ក្នុងចំណោមប្រទេសចំនួន១៦៨ ដែលត្រូវបានជ្រើសរើសដើម្បីវាយតម្លៃ។ នៅឆ្នាំ ២០១៤ កន្លងទៅ ប្រទេសកម្ពុជាទទួលបានពិន្ទុ ២១ និងមានចំណាត់ថ្នាក់១៥៦ ក្នុងចំណោមប្រទេសចំនួន១៧៥។

សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយ គឺជាសូចនាករដែលត្រូវបានគេប្រើយ៉ាងទូលំទូលាយសម្រាប់វាស់វែងពីទំហំនៃអំពើពុករលួយ។ វាឆ្លុះបញ្ចាំងពីការយល់ឃើញរបស់អ្នកឯកទេស អាជីវករ និងសាធារណៈជនទូទាំងពិភពលោកដែលបានដឹងព័ត៌មាន ព្រមទាំងមានការផ្ទៀងផ្ទាត់ជាមួយប្រភពទិន្នន័យរបស់ស្ថាប័នដែលមានកិត្តិនាមជាច្រើន។ វិនិយោគិនជាច្រើនបានពឹងផ្អែកលើសន្ទស្សន៍មួយនេះក្នុងការធ្វើធុរកិច្ចតាមប្រទេសនានា ហើយការស្រាវជ្រាវបានបង្ហាញនូវទំនាក់ទំនងគ្នាយ៉ាងស្អិតរមួតរវាងពិន្ទុនៃការយល់ឃើញពីអំពើពុករលួយ និងកំណើននៃកម្រិតវិនិយោគបរទេស។

លោក **ឱក សេរីសោភក្តិ៍** ប្រធានក្រុមប្រឹក្សាភិបាលនៃអង្គការតម្លាភាពកម្ពុជា បានមានប្រសាសន៍ថា *"លទ្ធផលសម្រាប់ប្រទេសកម្ពុជាក្នុងសន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយឆ្នាំ២០១៥នេះ បានឆ្លុះបញ្ចាំងថា ការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការធ្វើកំណែទម្រង់ និងការប្រយុទ្ធប្រឆាំងអំពើពុករលួយនៅមិនទាន់មានប្រសិទ្ធភាព និងគ្រប់គ្រាន់នៅឡើយទេ"*។ លោកបានបន្តទៀតថា *"ខណៈដែលការធ្វើកំណែទម្រង់វិស័យមួយចំនួន ត្រូវបានកត់សម្គាល់ និងទទួលបានការស្វាគមន៍ វាគឺជាការចាំបាច់ណាស់ដែលរដ្ឋាភិបាលត្រូវបន្តធ្វើកំណែទម្រង់ ទៅលើស្ថាប័នសាធារណៈនានាដោយផ្តោតទៅលើស្ថាប័នសំខាន់ៗ ដូចជាប្រព័ន្ធតុលាការ និងស្ថាប័នអនុវត្តច្បាប់ ព្រមទាំងស្ថាប័នដែលផ្តល់សេវាសាធារណៈជាដើម"*។

ពិន្ទុសម្រាប់សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយរបស់ប្រទេសកម្ពុជានៅឆ្នាំ២០១៥នេះ បានបង្ហាញថា ប្រទេសកម្ពុជានៅតែជាប្រទេសមួយដែលមានកម្រិតអំពើពុករលួយខ្ពស់នៅឡើយ។ ដូច្នេះ មានចំនុចជាច្រើនទៀតដែលគួរខិតខំធ្វើឲ្យប្រសើរឡើង ហើយក្នុងនោះដែរ រាជរដ្ឋាភិបាលកម្ពុជាគួរផ្តល់អាទិភាពដល់ការធ្វើកំណែទម្រង់អភិបាលកិច្ចក្នុងវិស័យសាធារណៈ។

ប៉ុន្មានឆ្នាំកន្លងមកនេះ អង្គការតម្លាភាពកម្ពុជាបានស្នើឲ្យរដ្ឋាភិបាលកម្ពុជាធ្វើកំណែទម្រង់ចំបងៗ និងមានលក្ខណៈជាប្រព័ន្ធនៅក្នុងស្ថាប័នជាតិសំខាន់ៗ ដោយផ្តោតលើកំណែទម្រង់ប្រព័ន្ធតុលាការ ការអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ច្បាប់ការពារសាក្សី និងអ្នករាយការណ៍ ធ្វើវិសោធនកម្មមាត្រាមួយចំនួននៃច្បាប់ប្រឆាំងអំពើពុករលួយ និងដោះស្រាយបញ្ហាបក្សពួកឬគ្រួសារនិយម និងបញ្ហាទំនាស់ផលប្រយោជន៍ក្នុងស្ថាប័នសាធារណៈ។ ប៉ុន្តែរហូតមកដល់បច្ចុប្បន្ន កិច្ចការទាំងនេះត្រូវបានអនុវត្តតិចតួចបំផុត និងពុំបានអនុវត្តឲ្យបានពេញលេញនោះទេ។ ដូច្នេះ អង្គការតម្លាភាពកម្ពុជាធ្វើការអំពាវនាវដល់រាជរដ្ឋាភិបាលជាថ្មីម្តងទៀតឲ្យអនុវត្តអនុសាសន៍ទាំងនេះ។

លោក **ព្រាប កុល** នាយកប្រតិបត្តិនៃអង្គការតម្លាភាពកម្ពុជា បានមានប្រសាសន៍ "*យើងទទួលស្គាល់ថាដើម្បីផ្លាស់ប្តូរការយល់ឃើញនិងទទួលបានលទ្ធផលវិជ្ជមាន ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ គឺត្រូវការពេលវេលា។ ទោះជាយ៉ាងណានេះក្តី វាជាការសំខាន់ដែលត្រូវអនុវត្តឲ្យត្រឹមត្រូវដោយផ្តោតលើបញ្ហាចំបងៗជាមុនសិន*"។ លោកបានបន្តទៀតថា "*បន្ថែមពីលើអនុសាសន៍ខាងលើ ការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញថាបច្ចុប្បន្ននេះ ប្រជាជនកម្ពុជាភាគច្រើនលើសលប់មានជំហរប្រឆាំងអំពើពុករលួយ និងត្រៀមខ្លួនជាស្រេចក្នុងការចូលរួមប្រយុទ្ធប្រឆាំងអំពើពុករលួយ ដូច្នេះហើយ យើងចង់ឃើញរដ្ឋាភិបាលបង្កើនលទ្ធភាពចូលរួមរបស់សាធារណៈជនក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយជាផ្នែកមួយសំខាន់នៃយុទ្ធសាស្ត្ររបស់ខ្លួនផងដែរ*"។

អង្គការតម្លាភាពកម្ពុជា ប្តេជ្ញាចិត្តធ្វើការជាមួយរាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធនានា ដើម្បីជម្រុញឲ្យមានកំណែទម្រង់បន្ថែមទៀតនិងដើម្បីលើកកម្ពស់តម្លាភាព សុចរិតភាព គណនេយ្យភាពនិងស្ថេរភាពនៃការអភិវឌ្ឍប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជា។

**ព័ត៌មានស្តីអំពីសន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយ**

សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៥ ដែលបង្ហាញពីទំហំនៃអំពើពុករលួយក្នុងវិស័យសាធារណៈតាមប្រទេសនីមួយៗដោយដាក់ពិន្ទុតាមមាត្រដ្ឋាន ពី 0 (ពុករលួយខ្លាំង) ទៅ១០០ (ស្អាតស្អំខ្លាំង)។ សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយ ត្រូវបានគណនា ហើយផ្ទៀងផ្ទាត់ជាមួយប្រភពទិន្នន័យរបស់ស្ថាប័នដែលមានកិត្តិនាមជាច្រើន ដែលឆ្លុះបញ្ចាំងពីទស្សនៈរបស់អ្នកឯកទេស និងពាណិជ្ជករមកពីទូទាំងពិភពលោក។

សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយឆ្នាំ២០១៥ ចាត់ចំណាត់ថ្នាក់និងលេខរៀង ១៦៨ ប្រទេសដោយពឹងផ្អែកទៅលើការស្ទង់មតិចំនួន ១២ ដែលឆ្លុះបញ្ចាំងពីទស្សនៈរបស់អ្នកឯកទេស និងពាណិជ្ជករមកពីទូទាំងពិភពលោក។ ប្រភពទិន្នន័យចំនួន ៧ ត្រូវបានប្រើប្រាស់ដើម្បីគណនាពិន្ទុសន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយរបស់ប្រទេសកម្ពុជាឆ្នាំ២០១៥។ ប្រភពទិន្នន័យទាំងនោះមានដូចជា៖ (១) សន្ទស្សន៍នៃការផ្លាស់ប្តូររបស់មូលនិធិ

Bertelsmann ឆ្នាំ២០១៦ (២) ចំណាត់ថ្នាក់ហានិភ័យប្រចាំប្រទេសរបស់ភ្នាក់ងារសេដ្ឋកិច្ច ឆ្នាំ២០១៥ (៣) ចំណាត់ថ្នាក់ហានិភ័យប្រចាំប្រទេសស្តីពីការយល់ដឹងជាសកល ឆ្នាំ២០១៤ (៤) ភ្នាក់ងារទីប្រឹក្សាហានិភ័យនយោបាយនិងសេដ្ឋកិច្ចទ្វីបអាស៊ីឆ្នាំ ២០១៥ (៥) ការវាយតំលៃស្ថាប័ននិងគោលនយោបាយប្រចាំប្រទេសរបស់ធនាគារពិភពលោក ឆ្នាំ២០១៤ (៦) ការស្ទង់មតិលើនីតិប្រតិបត្តិរបស់វេទិកាសេដ្ឋកិច្ចពិភពលោក (EOS) ឆ្នាំ២០១៥ (៧) សន្ទស្សន៍នីតិរដ្ឋរបស់គម្រោងយុត្តិធម៌ ពិភពលោកឆ្នាំ២០១៥។ ដើម្បីទទួលបានព័ត៌មានពីឯកសារយោងពេញលេញ នៃប្រភពទិន្នន័យទាំង១២ ក៏ដូចជា ប្រភេទនៃអ្នកឆ្លើយតប និងកម្រងសំនួរ សូមស្វែងរកឯកសារតាមរយៈ www.transparency.org៕


<u>សម្រាប់ការធ្វើបទសម្ភាសន៍សូមទំនាក់ទំនង៖</u>

លោក ឱក សេរីសោភ័ក្ត្រ ប្រធានក្រុមប្រឹក្សាភិបាលនៃអង្គការតម្លាភាពកម្ពុជា ទូរស័ព្ទលេខ ០១២ ៨១៥ ៣០២

លោក ព្រាប កុល នាយកប្រតិបត្តិនៃអង្គការតម្លាភាពកម្ពុជា ទូរស័ព្ទលេខ ០១២ ៨៧៧ ៨៣៣

ឬតាមរយអ៊ីម៉ែល kolpreap@ticambodia.org


###

Transparency International is the civil society organisation leading the fight against corruption